# ពាក្យហៅសាច់ញាតិ ក្នុងសិលាចារឹកខ្មែរ (ភាគ២)

នៅក្នុងអត្ថបទភាគ១ បានបង្ហាញអំពីពាក្យហៅញាតិជា ជីដូនជីតា និងឪពុកម្ដាយ តាមរយៈសិលាចារឹករួចមកហើយ[១]។ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញពាក្យបុរាណទាំងនោះជាបន្តទៅទៀត។

**បង៖** នៅសម័យកណ្ដាល យើងប្រទះឃើញសំណេរពាក្យនេះសរសេរច្រើនរបៀបជា **បោង បោង** និង **បង**។ នៅសម័យមុនអង្គរ និងអង្គរ យើងពុំប្រទះឃើញពាក្យនេះទេ ប្រទះឃើញតែពាក្យ **ត្បោង** និង **ត្បោង** ដែលមានន័យថា **ច្បង កូនបង**។ ថ្វីដ្បិតតែយើងពុំប្រទះពាក្យ **បង** នៅសម័យមុនអង្គរនិងអង្គរ តាមរយៈសិលាចារឹកក្ដី ក៏យើងអាចធ្វើបុនស្ថាបនកម្ម (Reconstruction) ឬកសាងពាក្យនោះឡើងវិញតាមរយៈពាក្យកម្លាយ **ត្បោង** និង **ត្បោង** ដែលក្លាយមកពីឫស ***បោង**។ ដូច្នេះពាក្យ **បង** កាលពីសម័យមុនអង្គរ និងអង្គរមានសំណេរជា ***បោង** ដែលបន្តប្រើនៅសម័យកណ្ដាលជា **បោង**។ យើងសូមជូនឃ្លាឧទាហរណ៍ ដែលដកស្រង់ពីសិលាចារឹកវត្តសសរមួយរយ ខេត្តក្រចេះដូចខាងក្រោម៖

«កន្ទេងកម្រតេងអញ្ចិត**ត្បោង** កូនិកន្ទេងកម្រតេងអញ្ចិគ្រីជយេន្ទ្រភា ចៅកន្ទេងអញ្ចិគ្រីន្ទ្របេន្ទ្រទេវី ចៅទ្វោតិវ្រះកម្រតេងអញ្ចិគ្រិន្ទ្រលោក» (K.១២៤៖ បន្ទាត់ទី៣-៦)។

ឃ្លាខាងលើនេះអាចប្រែសម្រួលបានថា «កន្ទេងគម្តែងអញ(ជាកូន)ច្បង កូនរបស់កន្ទេងគម្តែងអញស្រីជយេន្ទ្រភា ចៅរបស់កន្ទេងអញស្រីទ្រីបេន្ទ្រទេវី ចៅទួតរបស់ព្រះគម្តែងអញស្រិន្ទ្រលោក។

**ប្អូន៖** ពាក្យនេះនៅសម័យមុនអង្គរ មានសំណេរជា **ប្អូន** និងនៅសម័យអង្គរ មានសំណេរជា **ផ្អូន ផឲិន ផ្អូន** និង **ផអូន** ដែលពាក្យទាំងនេះជាពាក្យកម្លាយមកពីឫស **ឲិន** និង **អូន** មានន័យថា **អូន**។ ខាងក្រោមនេះជាឧទាហរណ៍ដកស្រង់ពីសិលាចារឹកអ្នកតា

[១] សូមមើល៖ https://ams.com.kh/khmercivilization/detail/18744។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ចារឹក K.១៨១ ដែលបង្ហាញពីមន្ត្រីម្នាក់មានងារនិងឈ្មោះថា វាបស្រី ជាប្អូនរបស់អភិបាលក្រុងដែលបានប្រើឱ្យទៅច្រូតស្រូវគេ ត្រូវទទួលទោសវាយខ្នង១០២រំពាត់។

«វាបិគ្រី តផ្អូនិម្រតាញ៑កុរុង៑ តតិប្រេច្រូត្តស្រុ តគិតិត្រានិណ្ឌ៝យប្វម្ពតាទន១០០-២» មានន័យថា វាបស្រីជាប្អូនម្រតាញកុរុងដែលប្រើច្រូតស្រូវ (សភា)ជម្រះក្តីដោយវាយខ្នង១០២រំពាត់[២]។

**រៀម៖** នៅក្នុងវចនានុក្រមខ្មែរ ពន្យល់ថាពាក្យនេះជារាជសព្ទ ឬពាក្យប្រើជាមួយព្រះរាជានិងព្រះរាជវង្សានុវង្ស ដូចជា **ព្រះរៀម សម្តេចព្រះរៀម**។ នៅក្នុងស្រទាប់មនុស្សទូទៅ ប្រើពាក្យនេះភ្ជាប់ជាមួយពាក្យ **ច្បង** ជា **រៀមច្បង**។ នៅសម័យមុនអង្គរ យើងមិនប្រទះឃើញពាក្យនេះទេ។ នៅសម័យអង្គរ ពាក្យនេះមានសំណេរច្រើនរបៀបដូចជា **អ្រឹំ អ្រ្យាំ** និង **អ្រ្យាម៑**។ ចំណែកឯនៅសម័យកណ្តាលសរសេរជា **រៀម** ដូចពេលបច្ចុប្បន្នដែរ។ ពាក្យនេះនាសម័យបុរាណមានប្រើដូចជា **អ្រ្យាំច្បោង៑** = **រៀមច្បង**, **អ្រ្យាំសហោទរ** = **បងបង្កើត/បងរួមផ្ទៃតែមួយ**, **វ្រះអ្រ្យាំ** = **ព្រះរៀម**។ ខាងក្រោមនេះជាឃ្លាឧទាហរណ៍៖

«វ្រះកម្រតេង៑អញ៑គ្រីកណ្ឌបណ្ឌិត**អ្រ្យាំ**សហោទរវ្រះកម្រតេង៑អញ៑គ្រីកវីគ្វរបណ្ឌិត» (K.៩១៩៖ បន្ទាត់ទី២២-២៣) អាចប្រែសម្រួលបានថា «ព្រះគម្តែងអញស្រីកណ្ឌបណ្ឌិតជាបងបង្កើតព្រះគម្តែងអញស្រីកវីស្វរបណ្ឌិត»។

**ក្មួន៖** នៅសម័យមុនអង្គរ ពាក្យនេះមានសំណេរជា **កោនិ កោន្ន កុនិ** និង **ក្វនិ**។ លុះមកដល់សម័យអង្គរ កាន់តែមានសំណេរសម្បូរបែបដូចជា **ក្វនិ ក្វន ក្វន្ន ក្វណិ ក្វណ្ណ ក្វានិ** និង **ក្វេនិ**[៣]។ នៅសម័យកណ្តាលមានសំណេរ **កួន កួន្ន** និង **កួណ**។ ខាងក្រោមនេះជាឃ្លាឧទាហរណ៍ស្រង់ពីសិលាចារឹកសម័យមុនអង្គរនិងអង្គរ៖

---

[២] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/7597។

[៣] សំណេរនេះ សង្កេតឃើញមានតែម្តងប៉ុណ្ណោះនៅក្នុងសិលាចារឹកវត្តភូ K.៣៦៦ ខណៈក្នុងសិលាចារឹកនេះដដែលសរសេរជា **ក្វនិ** ចំនួន១៧ដង។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

«អ្មេបន្ទៅ១ កុក្មោសិ១ អ្មេទ្រោងិ១ **កោនិ**កុ២ កុស្រី១ **កោនិ**កុ កុចាហ្វ១ កុយេសាយិ១ **កោនិ**កុ៣ កុយេមាយិ១ **កោនិ**កុ១ កុយោងិកនិ១ **កោនិ**កុ កុយង៉ាហ្វ១ កុយមា១ **កោនិ**កុ២ កុយតងិ១ **កោនិ**កុ២ កុម្ទេងិ១ **កោនិ**កុ២» (K.៤៥១ត្បូង៖ បន្ទាត់៧-១០) ដែលមានន័យថា «មេបន្ទៅ១ កុៈក្មោស១ មេទ្រោង១និងកូន២ កុស្រី១(និង)កូន កុចាហ្វ១ កុយេសាយ១និងកូន៣ កុយេមាយ១និងកូន១ កុយោងកន១និងកូន កុយង៉ាហ្វ១ កុយមា១និងកូន២ កុយតង១និងកូន២ កុរម្ទេង១និងកូន២»។

«មានិក្វានិម្វាយិដ្នះតេងិក្រ្ស្ណា» (K.៦១១ខ៖ បន្ទាត់៤) មានន័យថា «មានកូនមួយឈ្មោះតេងក្រឹស្ណា»។

**ចៅ៖** នៅសម័យមុនអង្គរ ពាក្យនេះមានសំណេរដូចបច្ចុប្បន្នដែរ។ ពាក្យនេះក៏ឃើញមាននៅក្នុងសិលាចារឹកមនបុរាណជា **cow**[៥] និងពាក្យមនទំនើបជា **cao**។ ពាក្យនេះក៏មាននៅក្នុងក្រុមភាសាមន-ខ្មែរដទៃទៀតផងដែរ[៦]។ ដូច្នេះពាក្យ **ចៅ** គឺជាពាក្យរបស់ក្រុមភាសាមន-ខ្មែរ។ នៅសម័យអង្គរ ពាក្យនេះមានសំណេរជា **ចៅ ចៅរ៑** និង **ចោ**[៧]។ លុះមកដល់សម័យកណ្ដាល ពាក្យនេះមានសំណេរជា **ចៅ ចៅរ ច្មៅ ចោរ ចោ ច្មោ** និង **ច្មោរ**។ ពាក្យ **ចៅ** នេះក៏ប្រើនៅក្នុងន័យម្យ៉ាងទៀតថា **ម្ចាស់** ផងដែរ ដូចជាពាក្យ **ព្រះចៅ** គឺ**ព្រះរាជា** ជាដើម។ នៅទីនេះ យើងពុំលើកយកពាក្យនេះមកពិភាក្សាឡើយ ដ្បិតពុំទាក់ទងនឹងប្រធានបទ។

---

[៤] **កុ** ជាឋានន្តរនាមរបស់អ្នកបម្រើភេទស្រី។ **កុយ** ជាឋានន្តរនាមរបស់អ្នកបម្រើភេទស្រីមានវ័យចំណាស់។

[៥] Jenner 2009: 137។

[៦] សូមអានបន្ថែម៖ Shorto, H. L., Sidwell, P., Cooper, D. L., & Bauer, C. (2006)។

[៧] សំណេរនេះ នៅសម័យអង្គរ សង្កេតឃើញមានតែ២ដងប៉ុណ្ណោះ។ នៅក្នុងសិលាចារឹកសំពេង K.២៥៤ ផ្ទាំងក បន្ទាត់ទី៤ ដែលអ្នកស្រាវជ្រាវមួយចំនួនអានជា «ចោ» នោះ ហាក់ពុំសមស្របទេ ដ្បិតវាមានរូបរាងជា «ចៅ» ច្រើនជាង។ គួរបញ្ជាក់ផងដែរថាសញ្ញាស្រៈនិស្ស័យ «ោ» និង «ៅ» នៅក្នុងសិលាចារឹកមានរូបរាងខុសប្លែកគ្នាបន្តិច ដែលនៅក្នុងស្ថានភាពចារចង្អៀត ឬអក្សរតូចដូចក្នុងសិលាចារឹកសំពេងនេះ អាចនាំឱ្យមានការច្រឡំគ្នា។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

## ពាក្យហៅសាច់ញាតិ ក្នុងសិលាចារឹកខ្មែរ (ភាគ២)

តាមរយៈពាក្យ ដែលបានលើកបង្ហាញកន្លងមកនេះ យើងសង្កេតឃើញថាពាក្យនៅសម័យកណ្តាល មានសំណេរច្រើនរបៀប ច្រើបបែបជាងសម័យមុនអង្គរនិងសម័យអង្គរ ។ ចំពោះសំណេរច្រើនរបៀបនៅសម័យកណ្តាល ក៏មានមតិរបស់អ្នកសិក្សាអក្សរសាស្ត្រនិងភាសាសម័យកណ្តាលមួយចំនួន ចាត់ទុកថាជាការធ្លាក់ចុះនៃអក្សរសាស្ត្រខ្មែរ ដ្បិតសំណេរគ្មានក្បួនខ្នាតច្បាស់លាស់ ឬមានអនាធិបតេយ្យ សរសេរតាមតំបន់ប្លែកៗគ្នា។ ជាពិសេសសំណេរនៅលើសាស្ត្រាស្លឹករឹត ក៏កាន់តែប្លែក ចម្រុះ និងច្រើនបែបជាងនៅលើសិលាចារឹកទៅទៀត។ នេះជាការមើលឃើញពីផ្នែកម្ខាង។ ប្រសិនបើយើងក្រឡេកមើល និងពិចារណាលើទិដ្ឋភាពម្ខាងទៀត នោះយើងនឹងអាចឃើញអ្វីផ្សេងមួយបែបទៀត។

នៅសម័យអង្គរ យើងសង្កេតឃើញថាសិលាចារឹកភាគច្រើនចារឡើង តាមព្រះរាជបញ្ជារបស់ព្រះមហាក្សត្រដែលបានត្រាស់បង្គាប់ ឬចារឡើងដោយទូលសុំទៅព្រះរាជា។ ចំណែកឯក្រុមចារទៀតនោះ ក៏មានក្រុមជាងដែលទទួលបន្ទុកចេញទៅធ្វើនិងចារសិលាចារឹកនោះផងដែរ។ ករណីផ្សេងទៀត ក៏ឃើញមានក្រុមជាងមូលដ្ឋានដែលទទួលភារៈចារសិលាចារឹកនោះផងដែរ។ ទោះបីជាមានក្រុមជាងចារផ្សេងគ្នា ប៉ុន្តែក្រុមទាំងនោះស្ថិតនៅក្រោមអំណាចកណ្តាលរួមគ្នាតែមួយ ដែលជាហេតុនាំឱ្យមានសំណេរឯកភាពគ្នាច្រើន។ ចំណែកសម័យកណ្តាលវិញ យើងឃើញថាអំណាចកណ្តាល មានភាពមិននឹងនរឯការចារសិលាចារឹកវិញ ក៏មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ត្រីរាជវាំងនិងព្រះរាជាទៀតដែរ។ មន្ត្រីតូចធំ ព្រះសង្ឃគ្រប់លំដាប់ថ្នាក់ អ្នកមានឋានៈក្នុងសង្គម ក្រុមអ្នកធ្វើធម្មយាត្រា អ្នកមកធ្វើបុណ្យនៅតាមបុរាណស្ថាននានា សុទ្ធតែអាចចារសិលាចារឹកបាន។ ម្យ៉ាងទៀត ទោះបីជាសំណេរទាំងនោះខុសប្លែកគ្នាក៏ដោយចុះ ក៏សំណេរទាំងនោះអាចជាកម្មវត្ថុនៃការសិក្សារកមូលដ្ឋាននៃសំណេរខ្មែរ ក្នុងទស្សនៈរបស់មនុស្សខ្មែរសម័យកណ្តាលផងដែរ។ ជាពិសេស គំនិតជាមូលដ្ឋាននៅក្នុងការបង្កើតសញ្ញានិងកត់ត្រាសូរដែលកើតឡើងថ្មី នាសម័យនោះផងដែរ។

(នៅមានត)

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## បញ្ជីរូបភាព







អត្ថបទដោយៈ ហ៊ុន ឈុនតេង




## ឯកសារយោង


Jenner, P. N.
2009. *A dictionary of pre-Angkorian Khmer*. Pacific linguistics, Research school of Pacific and Asian studies, the Australian national University.

Shorto, H. L., Sidwell, P., Cooper, D. L., & Bauer, C.
2006. *A Mon-Khmer comparative dictionary*. Pacific Linguistics, Research School of Pacific and Asian Studies, The Australian National University.


អត្ថបទដោយៈ ហ៊ិន ឈុនតេង